Responsible Business Alliance
Advancing Sustainability Globally

# RBA Voices

## ការបណ្ដុះបណ្ដាលសម្រាប់កម្មករនិយោជិត

# ការណែនាំអំពីឧបករណ៍ផ្តល់មតិកែលម្អ RBA Voices







RBA
កម្មវិធីចល័ត
និងបច្ចេកវិទ្យា
សំឡេងកម្មករ
និយោជិត

- RBA Voices using state of the art infrastructures such as **Tableau BI tool, AWS cloud** and has **ISO27001** certification for data security.

# កម្មវិធីរបស់កម្មករនិយោជិតមើលជាភាសារបស់ពួកគេប៉ុណ្ណោះ







កម្មវិធី ឬទម្រង់វិបប្រើប្រាស់ភាសាដើមក្នុងឧបករណ៍ (ផ្ទាំងបង្ហាញ) របស់ពួកគេ

ការគាំទ្រភាសាដើម (សម្រាប់អ្នកដាក់បញ្ជូន) សម្រាប់ភាសា (កម្មវិធី) ខាងក្រោម៖

- ភាសាចិន សាមញ្ញ
- ភាសាអង់គ្លេស
- ភាសាវៀតណាម
- ភាសាអាល្លឺម៉ង់
- ភាសាបារាំង
- ភាសាបាហាសា ឥណ្ឌូនេស៊ី
- ភាសាបាហាសា ម៉ាឡេ
- ភាសាអេស្ប៉ាញ
- ភាសាថៃ
- ភាសាអ៊ីតាលី
- ភាសាន័រវេស
- ភាសាចិន បុរាណ
- ភាសាខ្មែរ
- ភាសាជប៉ុន
- ភាសាកូរ៉េ
- ភាសាតាមិល
- ភាសានេប៉ាល់
- ភាសាបង់កាលី
- ភាសាអ៊ូឌូ
- ភាសាអារ៉ាប់
- ភាសាតួកគី
- ភាសាព័រទុយហ្គាល់

API បកប្រែរបស់ Microsoft សម្រាប់ចន្លោះផ្លាស់ប្តូរព័ត៌មាន (ជាង 100 ភាសា)

# វិធីបង្កើតគណនីនៅលើថ្នាលនេះ

1. ដោយប្រើកម្មវិធីអាន QR កូដលើទូរសព្ទរបស់ពួកគេ រួចស្កេន QR កូដពិសេសនឹងនាំពួកគេទៅកាន់ទំព័របង្កើតគណនី។
2. ទំព័រនឹងមានសភាពខុសគ្នាអាស្រ័យលើថាតើពួកគេកំពុងប្រើប្រាស់កម្មវិធី RBA Voices ពេញ ឬប្រើតែឧបករណ៍ផ្តល់មតិកែលម្អ។
3. ទំព័រនេះនឹងសម្របទៅតាមភាសាដែលឧបករណ៍ប្រើប្រាស់។




ផ្ទាំងបង្ហាញសម្រាប់ការចុះឈ្មោះលើកម្មវិធី




ការចុះឈ្មោះលើទម្រង់វិបសម្រាប់ផ្តល់មតិកែលម្អ

# អេក្រង់ចុះឈ្មោះរបស់កម្មករនិយោជិត




1. កម្មករនិយោជិតគួរតែចងចាំ/រក្សាទុកឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់របស់ពួកគេ។
2. ប្រសិនបើកម្មករនិយោជិតចង់ឃើញការឆ្លើយតបពីរោងចក្រ ពួកគេអាចបញ្ចូលអាសយដ្ឋានអ៊ីមែលបាន។
3. គួរវាយបញ្ចូលលេខកូដផ្ទៀងផ្ទាត់ក្នុងរយៈពេល 30 នាទីបន្ទាប់ពីបង្កើតគណនី ប្រសិនបើបញ្ចូលអាសយដ្ឋានអ៊ីមែល។




ចូលប្រើវីដេអូបង្រៀន

# ធនធានកម្មករនិយោជិត




វីដេអូបង្រៀន




សំណួរសួរញឹកញាប់លើឧបករណ៍

# កម្មករនិយោជិតថ្មីមើលឃើញបញ្ហា/ប្រភេទ









# វិធីដាក់បញ្ជូនមតិកែលម្អ/បណ្ដឹងតវ៉ា

1. ចុចលើរូបតំណាង ឧបករណ៍ផ្ដល់មតិកែលម្អ (Feedback Tool) ប្រសិនបើកម្មវិធី។ ពុំនោះទេ ប្រហែលជាអ្នកស្ថិតនៅក្នុងផ្ទាំងបង្ហាញរបស់ឧបករណ៍ផ្ដល់មតិត្រឡប់ស្រាប់ហើយ។
2. ចុច ដាក់បញ្ជូនសំណើ (Submit a Request)
3. ជ្រើសរើស ប្រភេទ (Category) នៅក្នុងផ្នែក ប្រភេទនៃការដាក់បញ្ជូន (Submission Category)។
4. វាយបញ្ចូលការពណ៌នាអំពីមតិកែលម្អ/បណ្ដឹងតវ៉ារបស់អ្នកនៅក្នុងផ្នែក ប្រធានបទ (Subject)។
5. វាយបញ្ចូលព័ត៌មានលម្អិតពាក់ព័ន្ធអំពីមតិកែលម្អ/បណ្ដឹងតវ៉ារបស់អ្នកនៅក្នុងផ្នែក ព័ត៌មានលម្អិត (Details)។ ការបញ្ចូលរូបភាព/ការស្កេននៃក្ដីកង្វល់របស់អ្នកគឺជាជម្រើសស្រេចចិត្ត។
6. អូសគ្រាប់រំកិលទៅ មតិកែលម្អអនាមិក (Anonymous feedback) ប្រសិនបើអ្នកចង់ផ្ដល់មតិកែលម្អដោយអនាមិក។
7. ប្រសិនបើអ្នកចង់ឱ្យរោងចក្រហៅទូរសព្ទទៅអ្នកវិញ សូមអូសគ្រាប់រំកិលទៅ ស្នើសុំការហៅទូរសព្ទត្រឡប់វិញ (Request a call back) និងផ្ដល់លេខទូរសព្ទរបស់អ្នក។ ជម្រើសនេះអាចមើលឃើញ បន្ទាប់ពីអ្នកជ្រើសរើសប្រភេទបញ្ហា។
8. ចុច ដាក់បញ្ជូន (Submit)។ បន្ទាប់ពីដាក់បញ្ជូនបានជោគជ័យ អ្នកគួរមើល លេខសម្គាល់ករណី (Case ID number) ដែលបានបង្កើតសម្រាប់គណនីរបស់អ្នក ព្រមទាំង QR កូដសម្រាប់រោងចក្រ។

# របៀបមើលការឆ្លើយតបទៅនឹងបណ្តឹងតវ៉ារបស់អ្នក

ទម្រង់វិប

1. ចូលគណនី RBA Voices របស់អ្នកដោយប្រើឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់របស់អ្នក ប្រសិនបើប្រើឧបករណ៍ ឬទម្រង់វិបផ្សេង។
2. ប្រសិនបើដាក់បញ្ជូនដោយអនាមិកនៅលើទម្រង់វិប ចូរពិនិត្យមើលគណនីរបស់អ្នកជាប្រចាំដើម្បីមើលថាមានការឆ្លើយតបទៅនឹងការដាក់បញ្ជូនរបស់អ្នកឬក៏អត់។
3. អ្នកនឹងទទួលបានការជូនដំណឹងអំពីការឆ្លើយតបតាមអាសយដ្ឋានអ៊ីមែល ដែលអ្នកបានប្រើដើម្បីបង្កើតគណនី ឬអ្នកក៏អាចកែអាសយដ្ឋានអ៊ីមែលបានផងដែរ។

កម្មវិធី

1. ប្រសិនបើប្រើកម្មវិធី ឧបករណ៍របស់អ្នកគួរតែរក្សាទុកព័ត៌មានសម្រាប់ចូលរបស់អ្នកដើម្បីជួយឱ្យអ្នកចូលគណនីវិញបាន។
2. ប្រសិនបើមានការឆ្លើយតប ឬព័ត៌មានថ្មី កម្មវិធីនឹងមានសញ្ញាចុចពណ៌ក្រហមនៅលើរូបតំណាងកម្មវិធី RBA Voices។



# ការបញ្ជូនទៅកម្រិតខ្ពស់ និងការវាយតម្លៃ

- រោងចក្រមានពេល 24-72 ម៉ោង ដើម្បីឆ្លើយតបនឹងការដាក់បញ្ជូនរបស់អ្នក។
- ប្រសិនបើមិនមានការឆ្លើយតបពីរោងចក្របន្ទាប់ពី 48 ម៉ោង នោះ នឹងអាចប្រើប៊ូតុង បញ្ជូនទៅកម្រិតខ្ពស់ (Escalate)។ ចុចលើប៊ូតុង បញ្ជូនទៅកម្រិតខ្ពស់ ដើម្បីលើកឡើងពីបញ្ហានេះទៅកាន់ RBA។
- ប៊ូតុងបញ្ជូនទៅកម្រិតខ្ពស់ ក៏អាចប្រើបាន បន្ទាប់ពីបិទការដាក់បញ្ជូនភ្លាមផងដែរ។ ចុចលើប៊ូតុងបញ្ជូនទៅកម្រិតខ្ពស់ ក្នុងករណីមិនពេញចិត្តនឹងលទ្ធផល។
- សូមចុចប៊ូតុងបញ្ជូនទៅកម្រិតខ្ពស់ក្នុងករណីមានការតបត។
- RBA នឹងឆ្លើយតបក្នុងរយៈពេល 7 ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីអ្នកបញ្ជូនទៅកម្រិតខ្ពស់។
- បន្ទាប់ពីរោងចក្របិទការដាក់បញ្ជូនរបស់អ្នក អ្នកនឹងមានឱកាសវាយតម្លៃដំណោះស្រាយដែលបានផ្ដល់ឱ្យ។ ភ្លាមៗបន្ទាប់ពីការបិទ អ្នកនឹងមើលឃើញរូបតំណាងវាយតម្លៃ។ វាយតម្លៃយោងតាមបទពិសោធន៍របស់អ្នក។



# ប្រទេសដែលមានមុខងារហៅចូល (Call-in) ត្រឹមខែកញ្ញា

ចិន | វៀតណាម | ជប៉ុន

កូរ៉េខាងត្បូង | ឥណ្ឌា | ម៉ាឡេស៊ី

ចិនតៃប៉ិ | តួកគី | ម៉ិកស៊ិក

ហ្វីលីពីន | ថៃ | អាល្លឺម៉ង់

សហរដ្ឋអាមេរិក | នេប៉ាល់




ប្រទេសអាចមានការប្រែប្រួល អាស្រ័យលើចំនួននៃការហៅដែលទទួលបានពីប្រទេសនីមួយៗ

ចុចលើ ទំនាក់ទំនង ដើម្បីមើលលេខទូរសព្ទដែលមាន (ឥតគិតថ្លៃ ឬក្នុងប្រទេស)

# វិធីបន្សល់ទុកសារជាសំឡេង

1. ហៅទៅលេខទូរសព្ទសម្រាប់ប្រទេសរបស់អ្នក។
2. នៅពេលមានការក្រើនរំលឹក សូមជ្រើសរើសភាសាដែលអ្នកចង់ប្រើសម្រាប់សារជាសំលេង
3. ត្រៀមខ្លួនផ្តល់លេខសម្គាល់ករណី ប្រសិនបើហៅដើម្បីតាមដានករណីដែលមានស្រាប់។ ប្រសិនបើដាក់បញ្ជូនករណីថ្មី សូមផ្តល់ឈ្មោះរោងចក្រ អាសយដ្ឋានដោយរាប់បញ្ចូលទាំងប្រទេស ព័ត៌មានលម្អិតអំពីបណ្តឹងតវ៉ារបស់អ្នក និងព័ត៌មានទំនាក់ទំនងរបស់អ្នក។
4. សារជាសំឡេងមានប្រវែងវែងបំផុតត្រឹម 30 វិនាទី។
5. មានតែបុគ្គលិក RBA ប៉ុណ្ណោះទើបទទួល និងពិនិត្យមើលសាររបស់អ្នកបាន។ សូមទុករយៈពេលរហូតដល់ 7 ថ្ងៃនៃថ្ងៃធ្វើការ មុននឹងយើងខ្ញុំអាចទាក់ទងទៅអ្នកតាមទូរសព្ទ ឬអ៊ីមែល។

Responsible Business Alliance
Advancing Sustainability Globally

# សូមអរគុណ!